**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ :....០០៦/២៤...........ក.ប/ស.ជ.ណ.ស.ជ.វ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ពាក្យធ្វើតេស្តវាយតម្លៃផ្អែកលើសមត្ថភាព ដើម្បីទទួលបានគុណវុឌ្ឍិជាតិ សម្រាប់ឆ្នាំ២០២៤

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រឹះស្ថានសិក្សាសាធារណៈ ឯកជន អង្គការ សមាគម សហគ្រាស គ្រឹះស្ថាន សិក្ខាកាម សិស្ស និស្សិត កម្មករ និយោជិត និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា ក្រសួងបានបង្កើតច្រកធ្វើតេស្តវាយតម្លៃផ្អែកលើសមត្ថភាពទទួលស្គាល់ការសិក្សាដែលមានពីមុន (ទ.ស.ម) លើសមត្ថភាពដែលទទួលបានពីការអប់រំ និងបណ្តុះបណ្តាលមិនផ្លូវការ ការសិក្សាក្រៅប្រព័ន្ធ និងសមត្ថភាពដែលទទួលបានពីបទពិសោធន៍នៅកន្លែងការងារ ដើម្បីទទួលបានគុណវុឌ្ឍិជាតិ។ ការធ្វើតេស្តវាយតម្លៃផ្អែកលើសមត្ថភាពនេះ ធ្វើឡើងដោយឥតបង់ថ្លៃ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានសិក្សាសាធារណៈ ឯកជន អង្គការ សមាគម សហគ្រាស គ្រឹះស្ថាន សិក្ខាកាម សិស្ស និស្សិត កម្មករ និយោជិត និងសាធារណជនទាំងអស់ដែលមានបំណងធ្វើតេស្តវាយតម្លៃផ្អែកលើសមត្ថភាព អាចចុះឈ្មោះតាមគេហទំព័រ https://tvet-erpl.com/home ឬទំនាក់ទំនងដាក់ពាក្យផ្ទាល់ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ នៅរៀងរាល់ម៉ោងធ្វើការ ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ចាប់ពីម៉ោង ៧:០០នាទីព្រឹក ដល់ម៉ោង ១៧:៣០នាទីរសៀល នៅតាមមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពដែលបានចុះបញ្ជិកា ដូចមានក្នុងតារាងឧបសម្ព័ន្ធ។

ថ្ងៃសុក្រ ៥រោច ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេង សួរ**

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត
- គ្រឹះស្ថាន អ.ប.វ. ក្រោមឱវាទ
  "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ កាលប្បវត្តិ

**តារាងឧបសម្ព័ន្ធ**
**មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ឆ្នាំ២០២៤**
**មានមុខរបរចំនួន៩ ដូចខាងក្រោម៖**

| **ល.រ** | **ឈ្មោះ និងអាសយដ្ឋាន មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព លេខទំនាក់ទំនង** | **មុខរបរ** |
|---|---|---|
| ១ | មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពព្រះកុសុមៈ<br>ផ្លូវសហព័ន្ធរុស្ស៊ី ភូមិចុងថ្នល់<br>ខាងកើត សង្កាត់ទឹកថ្លា<br>ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>012 610 321 / 015 610 321<br>Telegram : 012 610 321 | ១.ការងារកំបោរ<br>២.ការដំឡើងពុម្ព<br>៣.ការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ<br>៤.សេវាកម្មកុំព្យូទ័រ<br>៥.សេវាកម្មរចនាក្រាហ្វិកដោយកុំព្យូទ័រ |
| ២ | មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពបាត់ដំបង<br>ផ្លូវជាតិលេខ៥ ភូមិរំចេក សង្កាត់រតនៈ<br>ក្រុង/ខេត្តបាត់ដំបង<br>លោក ស្វាយ ចំប្ញទ្ធិ<br>Telegram : 012 212 686<br>លោក កាន់ ស្រ៊ុន<br>016 522 206 | ១.ការងារកំបោរ<br>២.ការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ<br>៣.សេវាកម្មកុំព្យូទ័រ<br>៤.សេវាកម្មថែទាំ និងជួសជុលរថយន្ត<br>៥.សេវាកម្មថែទាំ និងជួសជុលអគ្គិសនីរថយន្ត<br>៦.សេវាកម្មថែទាំ និងជួសជុលម៉ាស៊ីនត្រជាក់រថយន្ត |
| ៣ | មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពអង្គរ<br>វិថីសម្តេចវិបុលបញ្ញា សុខ អាន ភូមិព្រៃគុយ<br>ឃុំអំពិល ស្រុកប្រាសាទបាគង<br>ខេត្តសៀមរាប<br>លោក មឿន ថាណាក់<br>Telegram : 012 225 113/010 42 51 12 | ១.ការងារកំបោរ<br>២.ការដំឡើងបណ្តាញបំពង់ទឹក<br>៣.សេវាកម្មកុំព្យូទ័រ<br>៤.ការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ |
| ៤ | មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពខេត្តតាកែវ<br>ភូមិ៣ សង្កាត់រការក្នុង ក្រុងដូនកែវ<br>ខេត្តតាកែវ<br>ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ២ ខាង<br>កើតរបងវិទ្យាល័យ ជា ស៊ីម តាកែវ<br>077 857 518 /015 857 518<br>Telegram : 015857518 | ១.ការងារកំបោរ<br>២.ការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ<br>៣.សេវាកម្មកុំព្យូទ័រ<br>៤.សេវាកម្មរចនាក្រាហ្វិកដោយកុំព្យូទ័រ |
| ៥ | មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពសៀមរាប<br>ភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម<br>ក្រុងសៀមរាប ខេត្តសៀមរាប<br>012 32 14 22 | ១.សេវាកម្មកុំព្យូទ័រ កម្រិត២<br>២.ការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ កម្រិត១<br>៣.ការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ កម្រិត២ |

| | | |
|---|---|---|
| ៦ | **មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពកំពត**<br>ភូមិ១ឧសភា សង្កាត់កំពង់កណ្តាល<br>ក្រុងកំពត ខេត្តកំពត<br>092 355 216 | ១.ការថែទាំ និងជួសជុលរថយន្ត<br>២.ការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ កម្រិត១<br>៣.ការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ កម្រិត២ |
| ៧ | **មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ស្វាយរៀង**<br>ភូមិមេភ្លើង សង្កាត់ស្វាយរៀង<br>ក្រុងស្វាយរៀង ខេត្តស្វាយរៀង<br>012 89 22 49 | ១.ការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ កម្រិត១<br>២.ការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ កម្រិត២ |
| ៨ | **មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពខេត្តក្រចេះ**<br>ភូមិអូរឫស្សីទី២ សង្កាត់អូរឫស្សី<br>ក្រុងក្រចេះ ខេត្តក្រចេះ<br>012 784 948<br>Telegram: 0883899991/012784948 | ១.ការងារកំបោរ<br>២.ការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ<br>៣.សេវាកម្មរចនាក្រាហ្វិកដោយកុំព្យូទ័រ |